ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ០២៦/២០ គ.ជ.ប.ជ.

# របាយការណ៍ត្រីមាសទី៤
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២០

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីកិច្ចខិតខំប្រឹងប្រែងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ បានសហការគ្នាផ្តល់ភាពស្របច្បាប់ជូនពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - អនុស្សរណៈនៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការការីតាសស្វីស ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩។
- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**"។

ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ**"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

# ខ. ការបង្ការ ទប់ស្កាត់

## ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

### ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ

ខ.១.១.១. វេទិកាអន្តរសាសនា

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសហការជាមួយអង្គការការីតាសកម្ពុជា ក្រសួងធម្មការ និងសាសនា និងមេដឹកនាំសាសនាធំៗនៅកម្ពុជា រៀបចំកម្មវិធីវេទិកាជាតិអន្តរសាសនា លើកទី៣ នៅកម្ពុជា ដើម្បីប្រារព្ធពិធីសូត្រធម៌អធិដ្ឋាន និងបញ្ជូនសារតាមបែបសាសនា ក្នុងខ្លឹមសារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅមជ្ឈមណ្ឌលពិពណ៌កោះពេជ្រ ដែលមានអ្នកចូលរួមប្រមាណ ១.៤១០អង្គ/នាក់។

ខ.១.១.២. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- ថ្នាក់ជាតិ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសហការជាមួយ ក្រសួង ស្ថាប័ន អង្គភាព អង្គការដៃគូពាក់ព័ន្ធ និងទូរទស្សន៍ BTV, PNN ផលិតសម្ភារផ្សព្វផ្សាយអប់រំ ខ្សែវីដេអូបទយកការណ៍ ស្តីពីអំពើជួញដូរមនុស្ស និងការសម្តែងសិល្បៈចម្រុះ ដើម្បីបញ្ជ្រាបការយល់ដឹងដល់អង្គពិធីទាំងមូល ក្នុងកម្មវិធីយុទ្ធនាការ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ លើកទី១៣ ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ ដែលភ្ញៀវអញ្ជើញចូលរួមមានដូចជា ថ្នាក់ដឹកនាំក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ អង្គទូតនានា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធ តំណាងផ្នែកសាសនា និយោជិត កម្មករ និយោជក លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបប្រមាណ ៣.៥០០អង្គ/នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

- ថ្នាក់ក្រោមជាតិ

- លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ចំនួន ១៥ ខេត្ត បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន ១៦លើក មនុស្សប្រមាណ ១០.៥៧៧នាក់ (ស្រី ២.៩៥៥នាក់)។

- ដោយឡែកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ទាំង២៥ និងគ្រឹះស្ថានសិក្សាគ្រប់កម្រិត ទាំងវិស័យរដ្ឋ និងឯកជន បានប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ដែលមានថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ចំនួន ៥.៤៤៣លើក មានអ្នកចូលរួមសរុបចំនួន ១.៥៨៧.៣៦៣នាក់ ស្រី ៩៦២.២៦៩នាក់ ក្នុងនោះមានៈ(បុគ្គលិកអប់រំចំនួន ៦២.១៧៨នាក់ ស្រី ២២.៩៧៦នាក់ និងសិស្សានុសិស្ស និស្សិត ចំនួន ១.៥២៥.១៨៥នាក់ ស្រី ៩៣៩.២៩៣នាក់)។

ខ.១.២.ការអប់រំផ្សព្វផ្សាយដោយផ្ទាល់

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" ដល់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានសរុបចំនួន **២៤.២៩៥**លើក មានអ្នកចូលរួមសរុបចំនួន **១.៥៦៧.៧៩៧**នាក់ (ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០១៩ មានចំនួន **១.២៣៣.៥៣៩**នាក់ គឺមានការកើនឡើងចំនួន ៣៣៤.២៥៨នាក់ ស្មើនឹង ២៧,០៩%) ក្នុងនោះស្ត្រីចំនួន ៨៣០.១៨៧នាក់៖ [illegible]

# តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤៨៩ | ៥៦.៩៧៥ | ៨.៩៩០ | | | |
| សរុប ក្រសួង ស្ថាប័ន | | ៤៨៩លើក | ៥៦.៩៧៥នាក់ | ៨.៩៩០នាក់ | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១១ | ៥.៣២២ | ២.៧០៧ | ៦ | ៣.១២៥ | ១.៩៤៧ |
| ២ | ខេត្តកណ្ដាល | ១.០០៨ | ៤៤.០៩៤ | ២០.៧៨២ | ២.២២២ | ១៧១.២០៣ | ៧៩.៩៥៣ |
| ៣ | ខេត្តបាត់ដំបង | ២.៤៩៧ | ១៣០.៩៤០ | ៦៥.៧៥៤ | ១.៣៦៦ | ៥១.១៧៤ | ២៥.០៨៣ |
| ៤ | ខេត្តពោធិ៍សាត់ | ២.០៦៣ | ២៧៩.៦៥៨ | ១៦២.៤២៥ | ៤២៤ | ១៧.៤៧៨ | ៩.២២០ |
| ៥ | ខេត្តសៀមរាប | ១.១៨៥ | ៧៨.២៤៥ | ៤៦.៩៨៤ | ៩១ | ៤.០២១ | ២.០៣៧ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៣.៦៨១ | ២០៧.៣៨៦ | ១០៩.៨៧៧ | ២.៣៣៤ | ៩៣.២៨៥ | ៥០.៤៤៩ |
| ៧ | ខេត្តកំពង់ចាម | ១.៦១៥ | ១០២.៥៨៧ | ៤៦.៧៥៣ | ១.០៧៣ | ៦៣.៩០៨ | ៧៥.៩១១ |
| ៨ | ខេត្តព្រះសីហនុ | ៥៥ | ៣.៧៦១ | ២.០៤៣ | ៩ | ៥៧២ | ១៨១ |
| ៩ | ខេត្តព្រះវិហារ | ១៩ | ៩.៣៥០ | ៤.៣៨២ | ៨ | ២.៣៤០ | ៩៧៥ |
| ១០ | ខេត្តស្វាយរៀង | ៨ | ៣៥ | ២៧ | ១.០១៣ | ៣៩.១៤៥ | ២៣.៣៨០ |
| ១១ | ខេត្តប៉ៃលិន | ២៣៤ | ៦.៧៦០ | ៣.១៨៣ | ១៥៩ | ៩.១៨៤ | ៣.២១៥ |
| ១២ | ខេត្តកោះកុង | ១៦ | ២៨២ | ២១៨ | ១៨១ | ៣៨.៤២៩ | ៤.៣២៨ |
| ១៣ | ខេត្តកំពត | ៦ | ៧៨ | ៣៥ | | | |
| ១៤ | ខេត្តកំពង់ធំ | ៦៩ | ១.២៤៦ | ៧៤៥ | ១៣ | ៥.៥៤៩ | ១.៣៩៨ |
| ១៥ | ខេត្តតាកែវ | ១.២៥០ | ៦៣.៨៤០ | ២៩.៥៦៩ | ៨៤៦ | ៣២.៦៥៨ | ១៤.៦៧៨ |
| ១៦ | ខេត្តក្រចេះ | ២៥ | ១.២២៥ | ៧៨៨ | ១ | ១៥៥ | ៥០ |
| ១៧ | ខេត្តកែប | ៤៧ | ១០.០៩៨ | ៦.៣២៧ | ៨៤ | ១៨.១៧៨ | ១៨.៧៨៤ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៥ | ១.០៤៤ | ៦៦៤ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ៥ | ៧៩ | ៤០ | ២៨ | ១.៨៤៣ | ១.០១៨ |
| ២០ | ខេត្តរតនគិរី | ៧៧ | ៣.៤១៥ | ១.៦៣៨ | ៥៥ | ៤.០៨៨ | ៩៦៦ |
| ២១ | ខេត្តព្រៃវែង | | | | ២ | ៥០៩ | ២៨៧ |
| ២២ | ខេត្តត្បូងឃ្មុំ | ៣ | ២.២១៧ | ១.០៥៥ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១ | ១៧ | ១០ | ៥ | ១.៧៨៩ | ៩៩៧ |
| ២៥ | ខេត្តមណ្ឌលគិរី | ៦ | ៥១០ | ៣៣៤ | | | |
| សរុប រាជធានី-ខេត្ត | | ១៣.៨៨៦លើក | ៩៥២.១៨៩នាក់ | ៥០៦.៣៤០នាក់ | ៩.៩២០លើក | ៥៥៨.៦៣៣នាក់ | ៣១៤.៨៥៧នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ២៤.២៩៥ លើក | | អ្នកចូលរួមចំនួន ១.៥៦៧.៧៩៧ នាក់ | | ចំនួនស្ត្រី ៨៣០.១៨៧ នាក់ | |

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំនានា របស់អង្គការដៃគូ*

| អង្គការ | *សកម្មភាព* | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
|---|---|---|---|---|
| សាម៉ារីតាន់ភឺស (ខេត្តបាត់ដំបង) | - បានផ្សព្វផ្សាយអប់រំអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ជនចំណាកស្រុក។ | ០២ | ១១០ | ៤២ |
| អង្គការ ឆាលហ្វាន់ និង CCPCR *(ខេត្តស្វាយរៀង)* | - សហការជាមួយអ្នកសម្របសម្រួលព័ត៌មានចំណាកស្រុក តាមមូលដ្ឋាន ធ្វើការផ្ដល់សេវាប្រឹក្សាយោបល់អំពីចំណាកស្រុក ដល់យុវជនស្ម័គ្រចិត្ត សិស្ស និងគ្រួសារក្នុងសហគមន៍ នៅខេត្តស្វាយរៀង។ | ០៤ | ១.០៦៥ | ២៦៨ |

| | | | | |
|---|---|---|---|---|
| | - សហការជាមួយក្រុមយុវជន និងអ្នកស្ម័គ្រចិត្តភូមិ រៀបចំការប្រជុំផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុក។ | ១២ | ៧២៩ | ៤៥៧ |
| We World/GVC *(ខេត្តសៀមរាប)* | - បានសហការជាមួយមន្ទីរការងារ និងបណ្ដុះបណ្ដាលខេត្ត ប្រជុំផ្សព្វផ្សាយ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស នៅស្រុកពួក និងស្រុកជីក្រែង ខេត្តសៀមរាប។ | ១៥ | ៤០៥ | ២៩៨ |
| ជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (ខេត្តកោះកុង) | - បានប្រជុំផ្សព្វផ្សាយ ស្ដីពីសិទ្ធិពលករនេសាទ និងច្បាប់នេសាទចេញដោយព្រះរាជក្រឹត្យថៃ លើការការពារពលករចុះទូកនេសាទ ដល់ក្រុមជួយខ្លួនឯង ក្នុងសហគមន៍។ | ៥ | ១២៨ | ៩៣ |
| សរុប | | ៣៩ លើក | ២.៥៣១ នាក់ | ១.២៧១ នាក់ |

**ខ.១.៣. ការផលិតឧបករណ៍ផ្សព្វផ្សាយ (IEC)**

- ខេត្តស្វាយរៀង

លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការ ឆាលហ្វាន និងCCPCR ធ្វើការតំឡើងផ្ទាំងប៉ាន់ណូថ្មី ស្ដីពីការអប់រំក្នុងការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស ចំនួន ០៦ផ្ទាំង និងប្ដូរប៉ាន់ណូចាស់ចំនួន ១៣ផ្ទាំង។

**ខ.១.៤. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក**

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖

ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) ធ្វើការផ្សព្វផ្សាយតាមរយៈបណ្ដាក្រុមហ៊ុនផ្ដល់សេវាកម្មទូរស័ព្ទចល័ត នូវសារអប់រំ ដើម្បីអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ នៅកម្ពុជា។

- ខេត្តសៀមរាប៖

មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាព អាជ្ញាធរ និងអង្គការពាក់ព័ន្ធ ធ្វើកម្មវិធី "យើងធ្វើបាន" និង "សន្ទនាមតិ" ដោយផ្សាយផ្ទាល់ ៣២លើក ចាក់ផ្សាយឡើងវិញ ៨៣លើក និងផ្សព្វផ្សាយស្ពតអប់រំសរុប ៥.៧៤៥លើក ។

- ខេត្តតាកែវ៖

ផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុបានចំនួន ០៥អត្ថបទ និង ៤៥លើក។

- ខេត្តកំពង់ចាម៖

មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត បានផ្សព្វផ្សាយតាមហ្វេសបុក នូវសេចក្ដីជូនដំណឹង ព័ត៌មានពាក់ព័ន្ធពលករ និងកិច្ចប្រជុំនានារបស់ក្រុមការងារទេសន្តរប្រវេសន៍។

**ខ.១.៥. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា**

- ថ្នាក់ជាតិ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

បានចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាថ្នាក់ជាតិក្រោមប្រធានបទ "ផលប៉ះពាល់នៃច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មកលើអ្នកប្រកបរបរផ្លូវភេទ " នៅសាលប្រជុំសណ្ឋាគារ សាន់វ៉េ រាជធានីភ្នំពេញ។

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)៖

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម
  - ធ្វើបទបង្ហាញ ក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងវិស័យកសិកម្ម នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង មាននិស្សិតចូលរួមចំនួន ៧៥០នាក់។
  - ជាវាគ្មិន ក្នុងកម្មវិធី "**ដឹងគិតយល់ជោគជ័យ**" លើប្រធានបទ "**យន្តការណ៍ និងគោលនយោបាយសម្រាប់ទេសន្តរប្រវេសន៍**" របស់វិទ្យុស្ត្រី FM១០៣.៥MHz ដោយបានធ្វើការផ្សាយផ្ទាល់តាមវិទ្យុ និងបន្តផ្ទាល់តាមហ្វេសប៊ុក។
- ឯកឧត្តម ឧត្តមសេនីឯក ស៊ុន រ៉ូ អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមជា
  - គ្រូបង្គោលធ្វើបទឧទ្ទេសនាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅសាលាហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាពពហុជាតិ ដល់កងអនុសេនាធំវិស្វកម្មសំណង់លេខ៤៩៥ ចំនួន ១៩៤នាក់ (ស្រី ១០នាក់)។
  - វាគ្មិនក្នុងវេទិកាថ្នាក់ជាតិក្រោមប្រធានបទ "**ផលប៉ះពាល់នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មកលើអ្នកប្រកបរបរផ្លូវភេទ**" អ្នកចូលរួមចំនួន ១៥៥នាក់ នៅសាលប្រជុំសណ្ឋាគារ សាន់វេ៉ រាជធានីភ្នំពេញ។
  - គ្រូបង្គោលធ្វើបទឧទ្ទេសនាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់សិក្ខាកាមកងវិស្វកម្មលេខ៣៩៦ ចំនួន ១៨៤នាក់ (ស្រី ១០នាក់) នៅសាលាហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាព ពហុជាតិ។

• ថ្នាក់ក្រោមជាតិ

- ខេត្តកំពង់ចាម៖
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិន នៅរាជបណ្ឌិត្យសភាកម្ពុជា ស្តីពីលំហូរពលករទេសន្តរប្រវេសន៍ អត្ថប្រយោជន៍ និងបញ្ហាប្រឈម ចំនួន ០១លើក មានអ្នកចូលរួមចំនួន ១០០នាក់។
  - បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីវិទ្យុជាតិភ្នំប្រុសភ្នំស្រី ក្រោមប្រធានបទ បញ្ហាប្រឈមរបស់ស្ត្រីដែលរៀបការនៅវ័យក្មេង ចំនួន ០១លើក។
- ខេត្តបាត់ដំបង៖

  មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិន ក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងឱកាសស្វែងរកការងារ នៅសាលាស្រុកសង្កែ ចំនួន ០១លើក ។
- ខេត្តក្រចេះ៖

  បានចូលរួមជាវាគ្មិនក្នុងកម្មវិធីបញ្ឈប់អំពើហឹង្សាលើស្ត្រី និងកុមារ តាមរយៈការផ្សាយសម្លេង និងការឡាយតាមហ្វេសបុក របស់វិទ្យុសម្លេងស្ត្រីខេត្តក្រចេះ ចំនួន ០១លើក។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ

### ខ.២.១.វិធានការជំនាញអន្តោប្រវេសន៍៖ ការគ្រប់គ្រងជនបរទេស

១. ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា សរុបចំនួន **១២២លើក** មនុស្សចំនួន ៥៥៥នាក់(ស្រី ១៧៦នាក់)។

២.ការបដិសេធមិនឲ្យចូលប្រទេស: ការពង្រឹង បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស លើជនបរទេសចូល-ចេញតាមបណ្តាច្រកទ្វារព្រំដែនអន្តរជាតិនានា ក្នុងខែនេះបានធ្វើការបដិសេធមិនឲ្យចូល ប្រទេសសរុបមនុស្សចំនួន ៣៨៧នាក់។

### ខ.២.២.ការគ្រប់គ្រងស្ថិតិរបស់នគរបាល៖ បច្ចុប្បន្នភាពចំណាកស្រុក

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពលើទិន្នន័យពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថានៅតែបន្តកើតមានឡើង ជាក់ស្តែងត្រឹមមាសទី៤ ឆ្នាំ២០១៩៖

*តារាងតាមដានបច្ចុប្បន្នភាពលើទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុក*

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| តុលា | ៣៤៣.១៨៧ | ១៣៧.០៤៩ | ៦.៣៣៤ | ២.៤៧២ | ២១៧.៤៩៧ | ៨២.៧៣៣ | ៦៥៤ | ២៧៨ | ១២៥.៦៩០ | ៥៤.៣១៦ | ៥.៦៨០ | ២.១៩៤ | ថយចុះ ២.០៩៧ |
| វិច្ឆិកា | ៣៤៦.៤១០ | ១៤៨.២២៧ | ៥.៦៧១ | ២.២៥២ | ២២១.១១៦ | ៩៨.០០១ | ៦៦២ | ២៨២ | ១២៥.២៩៤ | ៥០.២២៦ | ៥.០០៩ | ១.៩៧០ | កើនឡើង ៣២.២៣ |
| ធ្នូ | ៣៥៧.៧៩១ | ១៥៩.២៤៣ | ៦.៧៤២ | ២.៧១៤ | ២៣១.៦០៨ | ១០៨.៣៨៩ | ១.៧៨៣ | ៧៥៤ | ១២៦.១៨៣ | ៥០.៨៥៤ | ៤.៩៥៩ | ១.៩៦០ | កើនឡើង ១១.២៨១ |

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារ ព្រំដែនគោកវរសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន **១៩៥លើក** ពុំបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។
- **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារ ព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន **១៤១លើក** (ព្រំដែនកម្ពុជា-វៀតណាម ១០៩លើក និងព្រំដែនកម្ពុជា-ឡាវ ៣២លើក)។

### ខ.២.៣.វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត (តាកែវ ព្រៃវែង មណ្ឌលគិរី រតនគិរី សៀមរាប ស្វាយរៀង ក្រចេះ កែប ព្រះសីហនុ និងខេត្តកោះកុង) បានធ្វើសកម្មភាពបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមគោលដៅបម្រើសេវាកម្សាន្ត ដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ ដូចមានតារាងខាងក្រោម៖

តារាងបច្ចុប្បន្នភាពគោលដៅសេវាកម្សាន្ត ដែលបានធ្វើការអប់រំដើម្បីបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស
និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងត្រីមាសទី៤ ឆ្នាំ២០១៩

| ត្រីមាសទី៤ ឆ្នាំ២០១៩ | | | |
|---|---|---|---|
| បរិយាយ | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ |
| ចំនួនគោលដៅ | ៥២១ គោលដៅ | ៤៣៥ គោលដៅ | ៥៩៧ គោលដៅ |
| ចំនួនមនុស្ស | ១២.២៨៨ នាក់ | ១.៩៥៩ នាក់ | ២.៣៦៩ នាក់ |
| ចំនួនស្ត្រី | ៥.០៣៧ នាក់ | ១.៤១៧ នាក់ | ១.៧៣៩ នាក់ |

ក្នុងនោះ៖

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ធ្វើបច្ចុប្បន្នភាពគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ៧៥គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ។
- ស្នងការដ្ឋាននគរបាលខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ៨៦លើក នៅស្វាយរៀង កំពង់ស្ពឺ តាកែវ ព្រៃវែង ក្រចេះ និងខេត្តព្រះវិហារ។

ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ

| ស្នងការដ្ឋានរាជធានី-ខេត្ត | ត្រីមាសទី៤ ឆ្នាំ២០១៩ | | |
|---|---|---|---|
| | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ |
| | ៣៥ លើក | ១៨ លើក | ៣៣ លើក |
| សរុប | ៨៦ លើក | | |

### ខ.២.៤.ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរូបភាពអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ៥២៦គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ចំនួន ៤២នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

### ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តសៀមរាប៖
  - មន្ទីរទេសចរណ៍ខេត្ត បាន (១)ចុះធ្វើបច្ចុប្បន្នភាពក្រុមនារីបម្រើការងារនៅតាមមូលដ្ឋានអាជីវកម្ម ផ្ទះសំណាក់ និងសណ្ឋាគារ ចំនួន ១៦លើក (២)ចុះត្រួតពិនិត្យការបិទបម្រាម នៅមូលដ្ឋានអាជីវកម្មម៉ាស្សា ចំនួន ០៤លើក ស្មើ ១០កន្លែង។ (៣)ចុះត្រួតពិនិត្យការបិទបំរាមអំពីការជួញដូរកុមារ ឬការនាំកុមារមិនទាន់គ្រប់អាយុចូលក្នុងបន្ទប់ស្នាក់នៅ (ករណីមិនមែនអាណាព្យាបាល) ចំនួន ២២កន្លែង (៤)ចុះត្រួតពិនិត្យខារ៉ាអូខេ ចំនួន ០៦កន្លែង។

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ និងវិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់ ស្តីពីការងារ រួមមាន អធិការកិច្ចសាមញ្ញ ចំនួន ០៣សហគ្រាស និងអធិការកិច្ចពិសេស ចំនួន ០៤សហគ្រាស។

- ខេត្តរតនគិរី៖

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចសាមញ្ញចំនួន ០៨លើក និងអធិការកិច្ចពិសេសចំនួន ១៧លើក និងអធិការកិច្ចពិសេសក្រៅកម្មវិធីចំនួន ០២លើក ក្នុងគោលបំណងពិនិត្យលើការងារអនុវត្តច្បាប់ ស្តីពីការងារបង្ការការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់ និងការប្រើប្រាស់ពលកម្មកុមារ។

- ខេត្តព្រះសីហនុ៖

សហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញ ដែលបានដាក់ចំនួន ១.១៣៣នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍)។

- **ខេត្តកំពង់ចាម៖**

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ចត្រួតពិនិត្យ និងទប់ស្កាត់ពលកម្មកុមារបានចំនួន ៤៤សហគ្រាស មានកុមារ ២០០នាក់ (កុមារី ៨៨នាក់)។

- ខេត្តស្វាយរៀង៖

បានសហការជាមួយអធិការដ្ឋានក្រុងបាវិត ចុះស្រង់ទិន្នន័យ និងធ្វើកិច្ចសន្យា នៅតាមគោលដៅរោងចក្រ ដែលសង្ស័យអាចពាក់ព័ន្ធការកេងប្រវ័ញ្ចកម្លាំងពលកម្មលើស្ត្រី និងកុមារ ចំនួន ០២លើក ស្មើ ០៨គោលដៅ។

- **ខេត្តតាកែវ៖**

- លោកស្រីអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចុះត្រួតពិនិត្យលើពលកម្មកុមារ នៅវិស័យឡជដ្ឋ ចំនួន ០១លើក។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមបណ្តារោងចក្រសហគ្រាស ដើម្បីត្រួតពិនិត្យមើលលក្ខខ័ណ្ឌការងារ ការអនុវត្តច្បាប់ ស្តីពីការងារ និងផ្សព្វផ្សាយ ច្បាប់ស្តីពីការធ្វើចំណាកស្រុក និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយខុសច្បាប់ សរុបចំនួន ០៣លើក អ្នកចូលរួមចំនួន ៨៤នាក់ (ស្រី ៦៤នាក់)។

- ខេត្តកោះកុង៖

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ និងផ្សព្វផ្សាយអប់រំដល់កម្មករ និយោជិក និងនិយោជក ចំនួន ០៣លើក។

- ខេត្តប៉ៃលិន៖

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡជដ្ឋ និងអាហារដ្ឋានចំនួន ៨០កន្លែង។

- **ខេត្តក្រចេះ៖**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះត្រួតពិនិត្យមណ្ឌល អង្គការដំណឹងល្អចំនួន ០៤ មានកុមារ ១៧នាក់ (កុមារី ០៥នាក់)។

## ខ.៤. ការផ្តល់ប័ណ្ណព្រំដែនដល់ប្រជាជនចល័តឆ្លងកាត់ព្រំដែន

- រដ្ឋបាលខេត្តចំនួន០២ គឺខេត្តបាត់ដំបង និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ២១.៨៧៨ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មានៈ
  - ខេត្តបាត់ដំបង ចំនួន ១៥.៣៦៣ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ៦.៥១៥ប័ណ្ណ។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការខាងអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីអង្គភាព៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត (រាជធានីភ្នំពេញ បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ធំ កណ្តាល មណ្ឌលគិរី ក្រចេះ ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ សៀមរាប ព្រះសីហនុ តាកែវ និងប៉ៃលិន។)

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ៣៥ករណី (បើប្រៀបធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៨ មានចំនួន ៣២ករណី កើនឡើងចំនួន ០៣ករណី ស្មើនឹង ៩,៣៧%)។

ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង ចំនួន ៤៧នាក់លើ៤៩នាក់ (ថយចុះចំនួន ០២នាក់ ស្មើនឹង ៤,២៥%) ក្នុងនោះស្រី ១២នាក់ អនីតិជន ០២នាក់ ជនបរទេស ០៨នាក់ សញ្ជាតិចិន ០៥នាក់ ថៃ ០១នាក់ រុស្ស៊ី ០១នាក់ និងអូស្ត្រាលី ០១នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ៦០នាក់លើ៥០នាក់ (កើនឡើងចំនួន ១០នាក់ ស្មើនឹង ២០%) ក្នុងនោះ មានអាយុក្រោម១៥ឆ្នាំ ៣៨នាក់ អាយុពី១៥-១៧ឆ្នាំ ០៧នាក់ និងពី១៨ឆ្នាំឡើង ១៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ១៩នាក់ និងប្រគល់ទៅគ្រួសារ ៤១នាក់)៖

*តារាងបូកសរុបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទប្រចាំខែនីមួយៗ*

| ល.រ | បរិយាយ | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| ១ | ខែតុលា | ១២ ករណី | ២២ នាក់ | ១៦ នាក់ | ថៃ១ រុស្ស៊ី១ |
| ២ | ខែវិច្ឆិកា | ១៥ ករណី | ២៤ នាក់ | ២១ នាក់ | ចិន៥ អូស្ត្រាលី១ |
| ៣ | ខែធ្នូ | ០៨ ករណី | ១៤ នាក់ | ១០ នាក់ | |
| សរុបត្រីមាសទី៤ | | ៣៥ ករណី | ៦០ នាក់ | ៤៧ នាក់ | ០៨ នាក់ |

បែកចេញជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ០៩ករណីលើ១០ករណី (ថយចុះ ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១២នាក់ (ស្រី ០៦នាក់) ជនបរទេស ០២នាក់ អូស្ត្រាលី ០១នាក់ និងរុស្ស៊ី ០១នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ២១នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១៥នាក់ អាយុពី១៥-១៧ឆ្នាំ ០៣នាក់ និងពី១៨ឆ្នាំឡើង ០៣នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៧នាក់ និងប្រគល់ទៅគ្រួសារ ១៤នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០៣ | ០៣ | ០៤ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០២ | ០៤ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០៦ | ០១ | |
| -ការទិញពេស្យាចាកុមារ | ០៣ | ១០ | ០៣ | អូស្ត្រាលី១ រុស្ស៊ី១ |
| *សរុប* | *០៩ករណី* | *២១ នាក់* | *១២ នាក់* | *០២ នាក់* |

## ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ២៦ករណីលើ២២ករណី (កើនឡើង ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៤១នាក់ (ស្រី ០៦នាក់ អនីតិជន ០២នាក់ ជនបរទេស ០៦នាក់ ចិន ០៥នាក់ ថៃ ០១នាក់)។

សង្គ្រោះជនរងគ្រោះចំនួន ៣៩នាក់ មាន: អាយុក្រោម១៥ឆ្នាំ ២៣នាក់ អាយុពី១៥-១៧ឆ្នាំ ០៤នាក់ និងពី១៨ឆ្នាំឡើង ១២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ១២នាក់ និងប្រគល់ទៅគ្រួសារ ២៧នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០១ | ០៥ | ចិន៥ |
| -សញ្ញារកម្ម(មានអនីតិជន) | ០៣ | ០៩ | ០៤ | |
| -សញ្ញារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០១ | ០៣ | ០២ | |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ | ០៤ | ០៣ | ថៃ១ |
| -រូបភាព និងសម្ភារៈអាសអាភាស | ០២ | ០២ | ០២ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៨ | ១០ | ០៩ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១០ | ១០ | ១០ | |
| *សរុប* | *២៦ ករណី* | *៣៩ នាក់* | *៣៥ នាក់* | *០៦ នាក់* |

## គ.២. កិច្ចការយុត្តិធម៌

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់ពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

### គ.២.១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៤៩ករណី ជនរងគ្រោះចំនួន ៦៣នាក់ (ស្រី ៥៨នាក់) អនីតិជន ២៥នាក់ (ស្រី ២២នាក់) ជនត្រូវចោទមានចំនួន ៥៤នាក់ (ស្រី ០៥នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ២៧ករណី តម្កល់ទុកឥតចាត់ការគ្មាន និងកំពុងចាត់ការចំនួន ២២ករណី ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប | ២ | ៣៦ | ៣ | ២២ | ៤២ | ៥ | ៧ | ០ | ២៧ | ០ | ២២ |
| ៤៩ | ៣៨ នាក់ | | ២៥ នាក់ | | ៤៧ នាក់ | | ០៧ នាក់ | | ៤៩ ករណី | | |

### គ.២.២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត សរុបមានចំនួន ៤១ករណី ជនរងគ្រោះចំនួន ៦៥នាក់ (ស្រី ៥២នាក់) អនីតិជន ៣១នាក់(ស្រី ២៣នាក់) ជនត្រូវចោទមានចំនួន ៥៦នាក់ (ស្រី ១២នាក់) នៅក្នុងឃុំចំនួន ៥២នាក់(ស្រី ១២នាក់) នៅក្រៅឃុំចំនួន ០៤នាក់ និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន ១៧ករណី លើកលែងចោទគ្មាន និងកំពុងចាត់ការចំនួន ២៤ករណី ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប | ៥ | ២៩ | ៨ | ២៣ | ៣៨ | ១២ | ៦ | ០ | ៣៨ | ១២ | ២ | ០ | ០ | ០ | ៤ | ០ | ១៧ | ០ | ២៤ |
| ៤១ | ៣៤ នាក់ | | ៣១ នាក់ | | ៥០ នាក់ | | ០៦ នាក់ | | ៥២ នាក់ | | | | ០៤ នាក់ | | | | ៤១ ករណី | | |

### គ.២.៣. ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន ៣៨ករណី ជនរងគ្រោះចំនួន ៤៨នាក់ (ស្រី ៤៧នាក់) អនីតិជន ៣២នាក់(ស្រី ៣១នាក់) ជនជាប់ចោទសរុប ៥៣នាក់(ស្រី ១១នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរគ្មាន ពិន័យជាប្រាក់គ្មាន រួចផុតពីបទចោទគ្មាន រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ១៥ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ១៨នាក់ នៅក្រៅឃុំ ០២នាក់ និងកំពង់ចាត់ការ ២៣ករណី) ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
| សរុប | ប | ស | ប | ស | ប | ស | ០ | ០ | ០ | ០ | ១៥ | ក្នុងឃុំ | ក្រៅឃុំ | |
| ៣៨ | ០ | ១៦ | ១ | ៣១ | ៤២ | ១១ | | | | | | ១៨ | ២ | ២៣ |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ សរុបចំនួន ៣.៣៥៣នាក់ (ស្រី ១.៧៧៨នាក់) ក្នុងនោះមកពី៖

- ប្រទេសថៃ ចំនួន ៤.២៨៩នាក់ ស្រីចំនួន ១.៧២០នាក់
- ប្រទេសចិន ចំនួន ២៩នាក់ ស្រីចំនួន ២៩នាក់
- ប្រទេសម៉ាឡេស៊ី ចំនួន ២៤នាក់ ស្រីចំនួន ១៨នាក់
- ប្រទេសវៀតណាម ចំនួន ០៩នាក់ ស្រីចំនួន ០៩នាក់
- ប្រទេសសឹង្ហបុរី ចំនួន ០២នាក់ ស្រីចំនួន ០២នាក់។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន ៣៣នាក់ (ស្ត្រី ៣០នាក់ កុមារី ០១នាក់) ក្នុងនោះមាន៖

- ក្រុមការងារការពារជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួល ជងរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ពីប្រទេសនានាសរុបចំនួន ២២នាក់ (ស្ត្រី ១៩នាក់ កុមារី ០១នាក់)៖ ប្រទេសចិន ១៦នាក់ ម៉ាឡេស៊ី ០៨នាក់ ថៃ ០២នាក់ និងប្រទេសវៀតណាម ០៧នាក់ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទ:/បង្ខំ ១៨នាក់ ជួញដូរកម្លាំងពលកម្ម ១២នាក់ ជួញដូរមនុស្ស ០១នាក់ និងងាយរងគ្រោះ ០២នាក់)។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះចំនួន ៥៣នាក់(ស្រី ៤៩នាក់) ដែលត្រឡប់ពីប្រទេសចិន ២៦នាក់ វៀតណាម ០៩នាក់ និងម៉ាឡេស៊ី ១៧នាក់ និងប្រទេសអារ៉ាប់ប៊ីសាអូឌីត ០១នាក់។ តាមការសម្ភាសបានឲ្យដឹងថាទៅតាមរយៈមេខ្យល់ ៣៩នាក់ និងទៅតាមក្រុមហ៊ុន ០៩នាក់ និងទៅដោយខ្លួនឯង ០៥នាក់។

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន ២៣៣លើក មនុស្សចំនួន ២.៨៤៣នាក់ (ស្រី ៨៥៩នាក់ កុមារ ២៧៨នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ៣០លើក មនុស្សចំនួន ១០៣នាក់ (ស្រី ៦៤នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ២០៣លើក មនុស្សចំនួន ២.៧៤០នាក់ (ស្រី ៧៩៥នាក់) កុមារចំនួន ២៧៨នាក់។

▪ **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

ស្នងការដ្ឋាននគរបាលខេត្ត ចំនួន៣ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម សរុបចំនួន ១៧៩លើក មនុស្សចំនួន២.៧០៧នាក់ (ស្រី ៧៩០នាក់) ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យ ចំនួន ១៣៧លើក មនុស្សចំនួន ២.៤៩៧នាក់ (ស្រីចំនួន ៧១១នាក់) អនីតិជនចំនួន ៣១១នាក់។
- ខេត្តបាត់ដំបង ចំនួន ២៦លើក មនុស្សចំនួន ១៧៥នាក់ (ស្រីចំនួន ៧៧នាក់) អនីតិជនចំនួន ០២នាក់។
- ខេត្តកោះកុង ចំនួន ១៦លើក មនុស្សចំនួន ៣៥នាក់ (ស្រីចំនួន ០២នាក់)។

## ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា ចំនួន ១១៩នាក់(ស្ត្រី ៥៦នាក់ កុមារ ៧០នាក់) រួមមាន៖

- ក្រុមការងារការពារជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួល ជងរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ១៤នាក់ (ស្ត្រី ១១នាក់ កុមារី ០៣នាក់) រួចបានបញ្ជូនទៅទទួលសេវាបន្ត នៅអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា អង្គការមេត្រីអន្តរជាតិ អង្គការក្តីសង្ឃឹមនិងយុត្តិធម៌ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និងអង្គការរតនៈអន្តរជាតិ។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួល និងផ្តល់ការស្នាក់នៅរយៈពេលខ្លីដល់កុមាររងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ១៩នាក់ (កុមារី ១៤នាក់) រួចបានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការតំណក់ទឹកគ្រួសារថ្មី និងអង្គការភឿនភឿន ដើម្បីស្នាក់នៅសិក្សាអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ មុននឹងបញ្ជូនទៅឲ្យគ្រួសារវិញ។
- **មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត** បានធ្វើការបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ៥២នាក់ (ស្រី ៤៥នាក់ កុមារី ០៧នាក់) ក្នុងនោះមានៈ សៀមរាប ០៨នាក់(ជួញដូរផ្លូវភេទ) ក្រចេះ ០១នាក់(រំលោភបំពានផ្លូវភេទ) រាជធានីភ្នំពេញ ៤១នាក់(ជួញដូរផ្លូវភេទ) កំពង់ធំ ០២នាក់(ជួញដូរមនុស្ស)។
- **អង្គការសង្គ្រោះនិងថែទាំស៊ីធីភញ** បានទទួលកុមាររងគ្រោះចំនួន ៣២នាក់ (កុមារី ៣១នាក់) ជាករណីជួញដូរមនុស្ស ១១នាក់ រំលោភបំពានផ្លូវភេទ ១៩នាក់ និងពេស្យាចារ ០២នាក់ ដើម្បីផ្តល់សេវា។

## ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រឡប់ទៅសហគមន៍វិញចំនួន ០៣នាក់ ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ០២នាក់ និងទូកនេសាទ ០១នាក់។
- មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ សហការជាមួយអង្គការដៃគូរ បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រឡប់ទៅសហគមន៍វិញចំនួន ១៣នាក់(ស្ត្រី) ជាករណីជួញដូរផ្លូវភេទ។
- មន្ទីរសង្គមកិច្ចខេត្តស្វាយរៀង សហការជាមួយអង្គការដៃគូរ បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រឡប់ទៅសហគមន៍វិញចំនួន ៣៧នាក់(ស្ត្រី ២០នាក់ កុមារ១៧នាក់) ជាករណីជួញដូរមនុស្ស ១០នាក់ អាជីវកម្មផ្លូវភេទ ១០នាក់ និងជួញដូរកម្លាំងពលកម្ម ១៧នាក់។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការងារបណ្តុះបណ្តាល

#### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបើកវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រីសង្គមកិច្ច ស្តីពីការគ្រប់គ្រងករណី នៅខេត្តមណ្ឌលគិរី។ | ០១ | ៥២ | ២៣ |
| ២ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការ AIM SWAT បើកវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ។ | ០១ | ២០ | ០៣ |
| ៣ | **ខេត្តស្វាយរៀង៖** | | | |
| | - លេខាធិការដ្ឋាន គ.ជ.ប.ជ បើកវគ្គបណ្តុះបណ្តាលដល់ក្រុមការងារថ្នាក់ស្រុក ស្តីពីការពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុករមាសហែក។ | ០១ | ៨៥ | ១៥ |
| | - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុន សហគ្រាសចំនួន១០ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីបំនិនជីវិត ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពតាមសហគ្រាស។ | ០១ | ១០៦ | ៨៧ |
| | - លេខាធិការដ្ឋាន គ.ជ.ប.ជ បបើកវគ្គបណ្តុះបណ្តាលដល់ក្រុមការងារថ្នាក់ស្រុក ស្តីពីការពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងក្រុង-ស្រុកចំនួន ៣ (ក្រុងបាវិត ស្រុកកំពង់រោទិ៍ និងស្រុកចន្ទ្រា)។ | ០៣ | ១៥៥ | ៥៤ |
| | - បានសហការជាមួយអង្គការឆាលហ្វានកម្ពុជា បើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារក្នុងការធ្វើចំណាកស្រុក និងការជួញដូរកុមារ នៅសាលប្រជុំសាលាខេត្តស្វាយរៀង។ | ០១ | ៣៩ | ០៩ |
| ៤ | **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ជ.ប.ជ បានបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្នាក់ឃុំ-សង្កាត់ ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ច និងច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ នៅរដ្ឋបាលសាលាក្រុងសៀមរាប។ | ០១ | ៨២ | ៣០ |
| ៥ | **ខេត្តត្បូងឃ្មុំ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដល់មេឃុំ ក្រុមប្រឹក្សាឃុំ គ.ក.ន.ក ឃុំ និងមេភូមិក្នុងឃុំចំនួន ៥ (កក់ កោងកាង ពពេល កណ្តាលជ្រុំ ដូនតី) ក្នុងស្រុកពញាក្រែក។ | ០១ | ១០០ | ១៣ |
| ៦ | **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋាន គ.ជ.ប.ជ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការនាំពលករទៅធ្វើការនៅក្រៅប្រទេសមិនស្របច្បាប់ និងវិធីសាស្ត្រក្នុងការចំណាកស្រុកទៅក្រៅប្រទេសប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅស្រុកបាធាយ ស្រុកចំការលើ និងស្រុកជើងព្រៃ។ | ០៣ | ១៥០ | ៧៤ |
| ៧ | **ខេត្តកំពត៖** លេខាធិការដ្ឋាន គ.ជ.ប.ជ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅក្នុងឃុំចំនួន ៣ (ក្រាំងស្បូវ ត្រមែង ក្រាំងស្នាយ) ក្នុងស្រុកឈូក។ | ០៤ | ១៩១ | ៥៩ |

| | | | | |
|---|---|---|---|---|
| ៨ | ខេត្តក្រចេះ៖ ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បានបើកវគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនលើកទី៣ ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ ដល់មន្ត្រីមកពី ស្នងការដ្ឋាន-អធិការដ្ឋាន-ប៉ុស្តិ៍នគរបាល មន្ទីរសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា។ | ០១ | ៣២ | ០៦ |
| ៩ | ខេត្តព្រះវិហារ៖<br>- ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បានបើកវគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនលើកទី៣ ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ ដល់មន្ត្រីមកពីស្នងការដ្ឋាន-អធិការដ្ឋាន-ប៉ុស្តិ៍នគរបាល មន្ទីរសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា និងមន្ទីរកិច្ចការនារី។ | ០១ | ៣០ | ០៦ |
| | - ស្នងការដ្ឋាននគរបាលខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីបញ្ញាបយេនឌ័រ ដើម្បីឲ្យដឹងពីសារៈប្រយោជន៍យេនឌ័រ និងនីតិវិធីបង្ការ ទប់ស្កាត់ និងបង្ក្រាបពាក់ព័ន្ធអំពើជួញដូរមនុស្ស ដល់មន្ត្រីនគរបាលខេត្ត។ | ០១ | ៧៧ | ៦១ |
| ១០ | ខេត្តស្ទឹងត្រែង៖ ស្នងការដ្ឋាននគរបាលខេត្ត បើកវគ្គបណ្តុះបណ្តាលស៊ើបអង្កេតច្បាប់បង្ក្រាបបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ | ០១ | ២០ | ០០ |
| ១១ | ខេត្តកោះកុង៖ អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស។ | ០១ | ២៦ | ១៨ |
| | សរុប | ២២ វគ្គ | ១.១៦៥ នាក់ | ៤៣៨ នាក់ |

#### ក.១.២.ការបណ្តុះបណ្តាលក្រៅប្រទេស

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ)
  បានចាត់មន្ត្រីដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "Promotion of Networking among ASEAN Countries on Anti- Trafficking in Person" នៅប្រទេសជប៉ុន។
- អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន
  បានចាត់មន្ត្រីជាន់ខ្ពស់ចំនួន ០២រូប ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមបណ្តាញអ៊ីនធើណេត (នៅប្រទេសថៃ)។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. សន្និសីទ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)
  -លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ បានអញ្ជើញចូលរួមនៅពិធីបើកសន្និសីទអគ្គរដ្ឋអាជ្ញាអាស៊ាន-ចិនលើកទី១២ ស្តីពីតួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទសណ្ឋាគារសុខាវីស៊ត ខេត្តសៀមរាប។

## ខ.២. កិច្ចប្រជុំ ក្នុងប្រទេស និងក្រៅប្រទេស

➢ **កិច្ចប្រជុំក្នុងប្រទេស**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

-សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបើកកិច្ចប្រជុំ ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូមនុស្ស របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន **២៧៦**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។

-លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ

**កិច្ចប្រជុំផ្ទៃក្នុង៖**

- ត្រៀមឆ្លើយតបទៅនឹងកម្រងសំនួរស្វ័យវាយតម្លៃរបស់ UNODC ទៅលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួមចំនួន **១១**នាក់ (ស្រី ០២នាក់) ។
- ត្រៀមរៀបចំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ៣២នាក់ (ស្រី ០៣នាក់)។
- ផ្សព្វផ្សាយពីវឌ្ឍនភាពការងារ និងផែនការសកម្មភាពអនុវត្តន៍បន្ត អ្នកចូលរួមចំនួន ៣៩នាក់ (ស្រី ០៤នាក់)។
- ត្រៀមរៀបចំទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៩ ស្តីពីបទយកការ និងរបាំសម្រាប់ទិវាជាតិ១២ធ្នូ។

**កិច្ចប្រជុំអន្តរក្រសួង៖**

- ពិគ្រោះយោបល់បច្ចេកទេសលើកទី២ ក្នុងចំណោមប្រទេសបញ្ជូនទាំង៣ កម្ពុជា ឡាវ មីយ៉ាន់ម៉ា (CLM) អ្នកចូលរួមចំនួន ២៦នាក់ (ស្រី ០៦នាក់)។
- ពិភាក្សាបន្ត ស្តីពីការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ ចំនួន ០២លើក អ្នកចូលរួមចំនួន **៧៧**នាក់ (ស្រី ២៥នាក់)។
- ពិនិត្យពិភាក្សាអំពីរបាយការណ៍រយៈពេល ១០ខែ ឆ្នាំ២០១៩ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន **១០៩**នាក់ (ស្រី ៥៩នាក់)នៅទីស្តីការក្រសួងមហាផ្ទៃ។
- ស្តីពីសេចក្តីព្រាងរបាយការណ៍ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តបន្ត អ្នកចូលរួមចំនួន៤៥នាក់។
- ស្តីពីទម្រង់កម្រងសំណួរលក្ខណវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃឆ្នាំ ២០១៩ របស់ គ.ជ.ប.ជ អ្នកចូលរួមចំនួន ២០នាក់។
- សេចក្តីព្រាងច្បាប់ ស្តីពី "ការពពោះជំនួស" អ្នកចូលរួមចំនួន ៤០នាក់ (ស្រី ០៧នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

បានរៀបចំកិច្ចប្រជុំ៖

- ស្តីពីការធ្វើបច្ចុប្បន្នភាពទម្រង់ទទួលជនរងគ្រោះ ដែលត្រូវធ្វើសមាហរណកម្ម និងស្វែងរកគ្រួសារ(ទម្រង់ទាំង៧ កម្មវិធីសមាហរណកម្ម) អ្នកចូលរួមចំនួន ២៨នាក់ (ស្រី ១៩នាក់) ជាមន្ត្រីជំនាញរបស់នាយកដ្ឋាន និងបុគ្គលិកអង្គការពាក់ព័ន្ធ។ BTtha

- ស្តីពីការប្រមូលធាតុចូល នៃកាដាក់ឲ្យប្រើប្រាស់សាកល្បងនូវទម្រង់ទាំង៧ នៃកម្មវិធីសមាហរណកម្ម អ្នកចូលរួមចំនួន ១០នាក់ ស្រី ០៧នាក់។

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈអន្តរជាតិ**

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ កម្រិតថ្នាក់ដឹកនាំបច្ចេកទេស នៃប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ មីយ៉ាន់ម៉ា) ស្តីពីតួនាទីប្រទេសបញ្ជូន ដើម្បីពង្រឹងកិច្ចការពារទេសន្តរប្រវេសន៍ អ្នកចូលរួមចំនួន ៨២នាក់ (ស្រី ១៩នាក់) នៅសណ្ឋាគារសុខាល័យ ខេត្តសៀមរាប។

➢ **កិច្ចប្រជុំក្រៅប្រទេស**

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

-លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម

- កិច្ចប្រជុំ ស្តីពីសន្និសីទរបស់រដ្ឋភាគី ប្រព្រឹត្តទៅនៅទីក្រុងវីយែនណា ប្រទេសអូទ្រីស ដែលមានការចូលរួមពីថ្នាក់ដឹកនាំ តំណាងឲ្យរដ្ឋាភិបាលនៃបណ្តាប្រទេសចំនួន៧៦ ជុំវិញពិភពលោក រៀបចំឡើងដោយ UNODC ដើម្បីពិនិត្យសម្រេចចុងក្រោយ ការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងពិធីសារនានា កំណត់ក្នុងសេចក្តីសម្រេចលេខ ៩/១។
- កិច្ចប្រជុំថ្នាក់កំពូលស្តីពី "**ពង្រាងបទបញ្ញត្តិ និងគោលនយោបាយរបស់ រាជរដ្ឋាភិបាល នៃការប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណែត**" នៅទីស្នាក់ការកណ្តាលសហភាពអាហ្វ្រិក នៃទីក្រុងអាឌីសអាបេបា នៅប្រទេសអេត្យូពី។

-លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ អញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីផែនការសកម្មភាពទស្សនៈកិច្ចសិក្សាផ្នែកការគ្រប់គ្រងមជ្ឈមណ្ឌល ដែលដឹកនាំដោយ ឯកឧត្តម ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅប្រទេសថៃ។

-លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី "**ការវាយតម្លៃលទ្ធផលកិច្ចសហការក្នុងការអនុវត្តកិច្ចព្រមព្រៀងរវាងកម្ពុជា និងវៀតណាម**" ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះ សម្រាប់ឆ្នាំ២០១៧-២០១៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

## ខ.៣. សិក្ខាសាលា

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

អង្គការកោរីតាសស្វីស បានសហការជាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ រៀបចំសិក្ខាសាលា ស្តីពី "**ការផ្តល់សេវាសមាហរណកម្មដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយចំណាកស្រុក**"ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានសិក្ខាកាមចូលរួមចំនួន ៥៥នាក់ នៅសណ្ឋាគារ ជីអេនស៊ីរាជធានីភ្នំពេញ។

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

បានរៀបចំសិក្ខាសាលាលើគោលនយោបាយ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដល់មន្ត្រីស.អ.យស្រុក មេឃុំ មេភូមិ មន្ត្រីគ.ក.ន.ក គ្រូបង្រៀន គ្រូពេទ្យ ប៉ូលីសប៉ុស្តិ៍ និងអ្នកពាក់ព័ន្ធ សរុបសិក្ខាមចូលរួមចំនួន ៦០នាក់ (ស្រី ១៣នាក់) នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម។

- ខេត្តកោះកុង៖

មន្ទីរទេសចរណ៍ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ សិក្ខាកាមចូលរួមចំនួន ៨១នាក់ (ស្រី ០៦នាក់) នៅវិទ្យាល័យថ្មសរ ឃុំថ្មសរ ស្រុកបូទុមសាគរ ខេត្តកោះកុង។

## ២.៤. ការទទួលជួបពិភាក្សាការងារ

▪ **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអនុញ្ញាតឲ្យលោកស្រី **Kristin Parco** តំណាងបេសកកម្ម IOM ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច ប្រចាំនៅកម្ពុជា ជួបពិភាក្សាការងារអំពីកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ (Global Compact for Migration)។
- លោកជំទាវ ឧត្តមសេនីយ៍ឯក ប៊ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានទទួលជំនួបពិភាក្សាការងារជាមួយ៖
  - ○ លោកស្រី Dr Nenette Motus នាយិកា IOM ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក និងសហការី កិច្ចពិភាក្សាផ្តោតសំខាន់លើការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងបញ្ហាពលករចំណាកស្រុក កិច្ចការពារស្ត្រី កុមារ និងកិច្ចសហប្រតិបត្តិការក្នុងការងារទទួលពលករបញ្ជូនត្រលប់ពីក្រៅប្រទេស។
  - ○ ប្រតិភូ ASEAN ACT ដឹកនាំដោយលោកស្រី ErinAnderson ក្នុងជំនួបនេះបានលើកបង្ហាញពីយុទ្ធសាស្ត្រ និងវិធីសាស្ត្ររបស់កម្មវិធី ASEAN ACT និងផែនការសកម្មភាព នៃបេសកកម្មរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងកិច្ចសហប្រតិបត្តិការជាមួយ គ.ជ.ប.ជ។
  - ○ លោក **គង់ វិទ្យា** នាយកប្រតិបត្តិ Cambodia ACTs ដើម្បីផ្តល់ជាអនុសាសន៍លើកិច្ចការងារបន្តរបស់ Cambodia Acts ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសកិច្ចសហការជាមួយ គ.ជ.ប.ជ។
  - ○ ជាមួយតំណាងស្ថានទូត អូស្ត្រាលី ស្តីពីការរំលោភបំពានផ្លូវភេទទៅលើកុមារគ្រប់ប្រភេទ។
  - ○ ស្ថានទូតអាមេរិកផ្នែកប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស គឺលោក PATRICK L. HAMILTON កិច្ចពិភាក្សាបានផ្តោតសំខាន់ទៅលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ដោយបានសង្កត់ធ្ងន់លើអំពើពុករលួយក្នុងជួរមន្ត្រីជំរុញការចាប់ខ្លួនជនល្មើស ពន្លឿនការកាត់ក្តី និងរបាយការណ៍។
- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានទទួលជំនួបជួបពិភាក្សាជាមួយក្រុមការងារ JICA Japan ដែលមកវាយតម្លៃសកម្មភាពការងារ ក្រោយវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់JICA នៅទីក្រុងតូក្យូ។

### ខ.៥. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៧១លើក មានអ្នកចូលរួមសរុប ៨០៨នាក់ (ស្រី ៥០៨នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៣០លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា ១០លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ៣១លើក។ (ឧបសម្ព័ន្ធ១)

## III. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្ស ជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិ ផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួន នៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ជាប្រចាំ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅអនុវត្តបន្ត ឆ្នាំ ២០២០

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្ម

នៃសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងារ របស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល និងការចុះតាមដានការអនុវត្តគោលនយោបាយ នៅថ្នាក់ក្រោមជាតិ ។

១២. ពង្រឹងសកម្មភាពទទួលពលករ ការស្រាវជ្រាវទិន្នន័យ និងផ្តល់សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ពីអាជ្ញាធរបរទេស និងពលករវិលត្រឡប់វិញនៅតាមច្រកព្រំដែនសំខាន់ៗ ។

ថ្ងៃ......................ខែ.............ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី............ខែ..........ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ គ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៧១លើក) មនុស្សចំនួន ៨០៨នាក់ (ស្រី ៥០៨នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | គ.ជ.ប.ជ សម្របសម្រួលចំនួន២០លើក អ្នកចូលរួមចំនួន៨៨នាក់ (ស្រី០៧នាក់)<br>▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានដឹកនាំប្រតិភូរបស់ អគ្គលេខាធិការដ្ឋាន ក.ជ.ក.ស ចុះតាមដានវាយតម្លៃការអនុវត្តច្បាប់ជាតិ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់នាយករដ្ឋមន្ត្រី ក្នុងការអនុវត្តអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងនារីភេទសីដរ (CEDAW) នៅសាលប្រជុំរដ្ឋបាលសាលា ខេត្តមណ្ឌលគីរី។<br>- បានអញ្ជើញចូលរួមជាគណៈអធិបតី កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន របស់គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- កិច្ចប្រជុំក្រុមការងាររបស់កម្មវិធីអាស៊ាន អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (AAPTIP) នៅសណ្ឋាគារភ្នំពេញ។<br>- សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវិភាគស្ថានភាពដំបូង លើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ិនធើណេត នៅកម្ពុជា នៅសណ្ឋាគារ ៧ មករា ខេត្តកំពង់ចាម។<br>- កិច្ចប្រជុំក្រុមការងារការពារជនរងគ្រោះ ដោយអំពើជួញដូរមនុស្សប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ និងការតាមដាន អនុវត្តកន្លងមករបស់ក្រសួង ស្ថាប័ន អង្គភាព និងអង្គការដៃគូ ដែលជាអនុប្រធាន និងសមាជិក ក្នុងគោលបំណងរកដំណោះស្រាយរួមគ្នា និងទិសដៅអនុវត្តបន្ត នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- ដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យវឌ្ឍនភាពការងាររបស់ក្រុមដែលបានបែងចែកលើលិខិតលេខ ១៧៥/១៩ ល.ប.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាលើឯកសាររូបភាព វីដេអូ បទយកការសម្រាប់ទិវាជាតិ ១២ធ្នូ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ដឹកនាំកិច្ចប្រជុំក្រុមការងារពិធីការ ស្តីពីការពិនិត្យវឌ្ឍនភាពការងារ និងបែងចែកតួនាទីភារកិច្ចលម្អិត សម្រាប់កម្មវិធីទិវាជាតិ១២ធ្នូ ឆ្នាំ២០១៩ អ្នកចូលរួមចំនួន ២៦នាក់ ស្រី០៥នាក់។<br>- ដឹកនាកិច្ចប្រជុំ ស្តីពីវឌ្ឍនភាពការងារតាមក្រុមនីមួយៗ ដែលបានទទួលខុសត្រូវក្នុងការរៀបចំទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៩ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន១២នាក់ ស្រី០២នាក់។<br>- ដឹកនាំកិច្ចប្រជុំដើម្បីត្រួតពិនិត្យការងារប្រចាំឆ្នាំ២០១៩ និងរបៀបរបបការងារឆ្លើយតបបានទាន់ពេលវេលា និងកាន់តែសុក្រិតភាព។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រវិទ្យាសាស្ត្រមូលដ្ឋានប្រើប្រាស់សម្រាប់ការតាមដាន និងវាយតម្លៃគម្រោង/កម្មវិធី ក្រោមអធិបតីភាព លោកជំទាវ **ប៊ុន ឈិត វាសនា** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស.) នៅសណ្ឋាគារ ៧មករា ខេត្តកំពង់ចាម។ |

BTtha

| | |
|---|---|
| | - ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការជ្រើសរើសពលករ ប្រកបដោយក្រមសីលធម៌ អ្នកចូលរួមចំនួន៥០នាក់ នៅសាលប្រជុំទន្លេបាសាក់២ រាជធានីភ្នំពេញ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៨១ច្បាប់ លិខិតចូល ២៧ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៣៦ច្បាប់ លិខិតចូល ៣៦ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែតុលា វិច្ឆិកា និងខែធ្នូ ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែតុលា វិច្ឆិកា និងខែធ្នូ ត្រីមាសទី៤ ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវិគី។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ៣៣ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ៣៩សកម្មភាព។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**<br>- លោកប្រធានក្រុម ដឹកនាំសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមេត្រី អន្តរជាតិ បានចុះមកពិនិត្យ និងតាមដាន ស្ត្រីកេស៊ីពរពោះជំនួស នៅខណ្ឌព្រែកព្នៅ និងខណ្ឌសែនសុខ។<br>- លោកអនុប្រធាន និងមន្ត្រី០១រូប បានចូលរួមសិក្ខាសាលា ស្តីពីគោលនយោបាយជាតិ អំពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២០ នៅកោះជនីយដ្ឋានទន្លេបាសាក់ ២។<br>- បានចូលរួមកិច្ចប្រជុំស្តីពីការសរសេររបាយការណ៍សិទ្ធិមនុស្សនៅកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវិភាគស្ថានភាពដំបូងពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ិនធើណេតនៅកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ស៊ូ អារ៉ាហ្វាត់** អភិបាលរងខេត្តបាត់ដំបង នៅសណ្ឋាគារ ឡឺប្រេស៊ីដង់ ខេត្តបាត់ដំបង។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការធ្វើឲ្យប្រសើរឡើងនៅសុខភាពជនអន្តោប្រវេសន៍ ក្រោមអធិបតីភាព ឯកឧត្តម **ស៊ីវ ហួង** រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅសណ្ឋាគារ អង្គរ ខេត្តសៀមរាប។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធអ៊ិនធើណេត ក្រោមអធិបតីភាពលោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារ រ៉ក់រ៉ូយ៉ាល់ ខេត្តកែប។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖** |

- លោកប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងវិស័យកសិកម្ម ក្រោមអធិបតីភាពឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នៅសាលាភូមិន្ទកសិកម្មចំការដូង។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖**

ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** អគ្គលេខាធិការរង បានអញ្ជើញចូលរួម

- កិច្ចប្រជុំ ស្តីពីការសរសេររបាយការណ៍សិទ្ធិមនុស្សនៅកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ អគារ S។
- ដឹកនាំកិច្ចប្រជុំពិនិត្យ និងផ្តល់ព័ត៌មានឆ្លើយតបទៅនឹងកម្រងសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារ នៃ អ.ស.ប ពាក់ព័ន្ធនឹងរបាយការណ៍ជាតិលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា។
- ដឹកនាំកិច្ចប្រជុំពិភាក្សាក្រុមការងារ ព័ត៌មានវិទ្យា រូបភាព បទយកការណ៍ និងផ្សព្វផ្សាយ សម្រាប់ទិវាជាតិ១២ធ្នូ ឆ្នាំ២០១៩។

▪ **ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ៖**

- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួម៖
  - ក្នុងកម្មវិធីយុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅរកភាពជាអ្នកដឹកនាំ#Girl2Leader Cambodia នៅវិមានរដ្ឋសភា ក្រោមអធិបតីភាពលោកជំទាវ កិត្តិសង្គហបណ្ឌិត **ឃួន ដារី** អនុប្រធានទី២ រដ្ឋសភា។
  - កិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារខមមីតកម្ពុជា ស្តីពីការពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពរយៈពេល១០ខែ ឆ្នាំ២០១៩ ដើម្បីផ្ញើជូនទៅ គ.ជ.ប.ជ និងរាយការណ៍ពីស្ថានភាពបច្ចុប្បន្ននៃអំពើជួញដូរមនុស្សនៅកម្ពុជា ដើម្បីកំណត់បញ្ហាប្រឈមថ្មី និងលើកទិសដៅបន្តឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី អ្នកចូលរួមចំនួន៣៨នាក់ ស្រី១៨នាក់ ទៅសាលប្រជុំទីស្តីការក្រសួងកិច្ចការនារី។
  - ដឹកនាំប្រជុំក្រុមការងារស្តីពី វឌ្ឍនភាពការងារដែលសម្រេចបាននៅចុងឆ្នាំ២០១៩ និងទិសដៅសម្រាប់អនុវត្តសម្រាប់ឆ្នាំ២០២០។
  - កិច្ចពិភាក្សាត្រៀមចូលរួមកិច្ចប្រជុំទ្វេភាគី ស្តីពី៖ ការត្រួតពិនិត្យឡើងវិញនូវការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីរវាងកម្ពុជា និងវៀតណាម អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ ហ៊ូ **សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី សាលប្រជុំទីស្តីការក្រសួងកិច្ចការនារី (ចំនួន០២លើក)។
  - សិក្ខាសាលាតាមដាន លើកម្មវិធីបង្កើតចំណេះដឹងរួមគ្នា ដើម្បីលើកកម្ពស់ទំនាក់ទំនងរវាងបណ្តាប្រទេសអាស៊ាន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅការិយាល័យ JICA ប្រចាំនៅកម្ពុជា។
- លោកអនុប្រធានក្រុម បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "**កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ**" ក្រោមអធិបតីភាព លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍៖**

BTha

| | |
|---|---|
| | ឯកឧត្តម ឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំសមិទ្ធិផលនៃការអនុវត្តគម្រោងឆ្នាំ២០១៩ និងការរៀបចំផែនការសកម្មភាពបន្តសម្រាប់អនុវត្តគម្រោង ILO-TRIANGLE ឆ្នាំ២០២០ ក្រោមការរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការ ILO នៅសណ្ឋាគារភ្នំពេញ។ |
| ក្រសួងសង្គមកិច្ច អតីតយុជន និងយុវនីតិសម្បទា | - បានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០២លើក ១.ពិធីប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២.ពិភាក្សាអំពីការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ (ចំនួន០២លើក)។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលារបស់អង្គការក្រោមឱវាទក្រសួងសង្គមកិច្ច ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធើណេតនៅកម្ពុជា (ខេត្តកំពង់ចាម)។<br>- បានចូលរួមកិច្ចប្រជុំរបស់ក្រុមការងារខេមមីតកម្ពុជា និងក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគ.ជ.ប.ជ នៅក្រសួងកិច្ចការនារី។<br>- បានចូលរួមកិច្ចប្រជុំនានាចំនួន០៣លើក និងបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ចំនួន០២លើក ១.ស្តីពី សិទ្ធិកុមារ និងសិទ្ធិស្ត្រី និង២.ការទុកកុមារនៅក្នុងគ្រួសារចិញ្ចឹម។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣១លើក អ្នកចូលរួមសរុបចំនួន ៦៨២នាក់ (ស្រី ៣៨៣នាក់)** | |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ<br>○ បានប្រជុំបូកសរុបរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែ និងត្រីមាសទី៣ ឆ្នាំ២០១៩ ចំនួន០៤លើក អ្នកចូលរួមចំនួន១៥៨នាក់ ស្រី ១០៤នាក់។<br>○ បានសហការជាមួយអង្គការ APLE រៀបចំកិច្ចប្រជុំ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ិនធើណេត ដល់ក្រុមការងារបច្ចេកទេសទាំង៦ របស់លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរពាក់ព័ន្ធ អ្នកចូលរួមចំនួន១៣នាក់ ស្រី០៧នាក់។ |
| ខេត្តកណ្តាល | - ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែចំនួន១៨លើក អ្នកចូលរួមចំនួន៤៣៤នាក់ ស្រី៣២៦នាក់។ |
| ខេត្តកោះកុង | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំរៀបចំផែនការសកម្មភាព របស់លេខាធិការដ្ឋានប្រចាំឆ្នាំ២០២០ អ្នកចូលរួមចំនួន២២នាក់ ស្រី១០នាក់។ |
| ខេត្តតាកែវ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល១០ខែ ឆ្នាំ២០១៩ អ្នកចូលរួមចំនួន៣៥នាក់ ស្រី១០នាក់។ |
| ខេត្តកំពង់ចាម | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំបូកសរុបរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១៩។ |
| ខេត្តព្រះវិហារ | - ស្ថាប័នតុលាការខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ រៀបចំកិច្ចប្រជុំ ស្តីពីយុត្តិធម៌អនីតិជន និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អ្នកចូលរួមចំនួន២២នាក់ ស្រី០៦នាក់។ |
| ខេត្តក្រចេះ | - បានរៀបចំកិច្ចប្រជុំបូកសរុបរបាយការណ៍រយៈពេល៩ខែ និងប្រចាំឆ្នាំ២០១៩ ចំនួន០២លើក ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ៦១នាក់ ស្រី៤៤នាក់។ |
| ខេត្តកំពង់ចាម | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំបូកសរុបរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែធ្នូ ឆ្នាំ២០១៩។ |